ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា    ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១១០ អនក្រ. បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់
# អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៩៩៩/១០ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ កុម្ភះ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០១/២០១ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការតែងតាំងអគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ភារកិច្ច និងការរៀបចំផ្នែកនានា របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីដែលហៅកាត់ថា " **ក.ជ.ក.ស** " ។

## ជំពូកទី ២

## តួនាទី និង ភារកិច្ច

**មាត្រា ២.-**

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និង គ្រប់គ្រងដោយ អគ្គលេខាធិការមួយរូប និង អគ្គលេខាធិការរងពីររូប ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានបេសកកម្មដាក់អោយដំណើរការនូវការងារតាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ជាសេនាធិការ របស់ **ក.ជ.ក.ស** ក្នុងការៈ

១- អនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និង របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ រួមមានៈ

- ការងារគ្រប់គ្រងមន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋាន

- ការគ្រប់គ្រងថវិកា និង ទ្រព្យសម្បត្តិ ដទៃទៀតរបស់ក្រុមប្រឹក្សា ដោយ អនុលោមតាម ការ សំរេច របស់ **គ.ជ.ក.ស**
- រៀបចំការប្រជុំសាមញ្ញ និងវិសាមញ្ញទាំងអស់ រួមទាំងការធ្វើកំណត់ហេតុ និងរបាយការណ៍ អំពីសកម្មភាពរបស់ **គ.ជ.ក.ស**

២- រៀបចំផែនការសកម្មភាពការងារ រយៈពេលខ្លី មធ្យម វែង បេស់ **គ.ជ.ក.ស**

៣- រៀបចំរបាយការណ៍ជាតិស្តីពីការ អនុវត្តន៍អនុសញ្ញាស្តីពីការ លុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំង នារីភេទ (CEDAW) ជូន **គ.ជ.ក.ស** ដើម្បីពិនិត្យនិងកែលំអដាក់ជូនរាជរដ្ឋាភិបាលសំរេច និងផ្ញើជូន អគ្គលេខាធិការ អង្គការសហប្រជាជាតិ

៤- ពិនិត្យតាមដានស្ថានភាពរបស់ស្ត្រីនៅកម្ពុជា ដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលដៅសន្និសីទកំពូលសកលលោកដើម្បីស្ត្រី

៥- ធ្វើសហប្រតិបត្តិការ និងសហការសំរបសំរួលជាមួយក្រសួងនានា អង្គការជាតិ និងអន្តរជាតិអង្គការក្រៅ រដ្ឋាភិបាល ដើម្បីអោយការងារ **គ.ជ.ក.ស** មានប្រសិទ្ធភាពខ្ពស់

៦- រៀបចំបណ្ណាល័យសំរាប់តំកល់ព័ត៌មាន និងឯកសារទាំងអស់ដែលពាក់ពន្ធ័ទៅនឹងស្ត្រី រួមមានឯកសារជាផ្លូវការ ឯកសារសំរាប់ការសិក្សាស្រាវជ្រាវ របាយការណ៍ ផែនការសកម្មភាព។

**មាត្រា ៥.~**

១-ថវិការរបស់ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីរួមមានៈ

ក- ថវិការដ្ឋ ដែលជាឧបសម្ព័ន្ធ នៃថវិការបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន។

ខ- ជំនួយផបត្តម្ភពីអង្គការអន្តរជាតិ ប្រទេសផ្តល់អំណោយ សប្បុរសជន ជាតិ ឬ បរទេស។

២-ប្រភពចំណូលទាំងអស់របស់ក្រុមប្រឹក្សា ក្រៅពីថវិការដ្ឋ ត្រូវបញ្ចូលក្នុងគណនី របស់ក្រុមប្រឹក្សា នៅក្នុងធនាគារអនុម័តដោយក្រុមប្រឹក្សា ដែលរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជាអាណាប័ក និងអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាអាណាប័កផ្ទេរសិទ្ធ។ ការប្រើប្រាស់ថវិកាក្រៅពីភារកិច្ច ដំណើរការប្រចាំថ្ងៃ ត្រូវមានការអនុញ្ញាតពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

៣-ការគ្រប់គ្រងថវិកា និងធនធានសម្ភារៈបរិក្ខារ របស់ក្រុមប្រឹក្សាត្រូវអនុវត្តតាមគោលការណ៍ ហិរញ្ញវត្ថុនៃ រាជរដ្ឋាភិបាល និងយោងតាមសំណូមពររបស់អ្នកផ្តល់ជំនួយ ។

៤- គណនី របស់ក្រុមប្រឹក្សា ក្រៅពីថវិការដ្ឋ ត្រូវត្រួតពិនិត្យដោយសវនករមួយក្រុម ដែលចាត់តាំងដោយក្រុមប្រឹក្សា និងតាមសំណូមពររបស់អ្នកផ្តល់ជំនួយ ។

៥- សេចក្តីរាយការណ៍ស្តីពីតុល្យភាព នៃការចំណូលចំណាយថវិកាសម្ភារៈរបស់ក្រុមប្រឹក្សាត្រូវរៀបចំឡើង និងដាក់ជូនសមាជិកា-សមាជិក ទាំងអស់របស់ក្រុមប្រឹក្សាដើម្បីពិនិត្យ និង ជ្រាបជាព័ត៌មាន ក្នុងរយៈពេលមិនហួសពីបីខែ បន្ទាប់ពីការជំរះបញ្ជីប្រចាំឆ្នាំនីមួយៗ ។

៦- ក្នុងករណីដែល **ក.ជ.ក.ស** មិនដំណើរការ ឬ ចប់បេសកម្ម ចំនួលក្រៅពីថវិការដ្ឋ ត្រូវផ្ទេរទៅក្រុមប្រឹក្សាណា ដែលមានបេសកម្មប្រហាក់ប្រហែល តាមការសំរេចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ **ក.ជ.ក.ស** មានរចនាសម្ព័ន្ធដូចតទៅ :

**១-ផ្នែកបូកសរុប និង ហិរញ្ញកិច្ច**

មានតួនាទីជួយដល់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក្នុងការអនុវត្តន៍ការងាររដ្ឋបាលប្រចាំថ្ងៃ និង ការងារហិរញ្ញកិច្ច ដោយមានភារកិច្ចដូចតទៅ :

- ចុះបញ្ជីរាល់លិខិតចេញ-ចូល ធ្វើលិខិតផ្សេងៗ បញ្ជូនលិខិត និង ទំនាក់ទំនងជាមួយសាធារណជន
- រៀបចំ និង អនុវត្ត នូវទំរង់បែបបទគ្រប់គ្រង មន្ត្រី បុគ្គលិក ដោយគោរព និង អនុវត្តច្បាប់ វិន័យ និង បទបញ្ជាផ្ទៃក្នុងរបស់ **ក,ជ,ក,ស**
- រៀបចំសាលប្រជុំធ្វើពិធីការ ធ្វើកំណត់ហេតុ របាយការណ៍ពីអង្គប្រជុំរបស់ **ក,ជ,ក,ស** និងអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ធ្វើរបាយការណ៍បូកសរុបការងាររបស់អគ្គលេខាធិការដ្ឋាន និងរបស់ **ក,ជ,ក,ស** រាល់ត្រីមាសនិងឆ្នាំ
- រៀបចំបណ្ណាល័យ ថែរក្សារាល់ឯកសារទ្រព្យសម្បត្តិរបស់ **ក,ជ,ក,ស**
- រៀបចំ និងធ្វើគំរោងថវិកាប្រចាំឆ្នាំ និងគំរោងផ្សេងៗ ទៀតរបស់ **ក,ជ,ក,ស**
- ធ្វើរបាយការណ៍ អំពីសកម្មភាពផ្នែករបស់ខ្លួន ជូនអគ្គលេខាធិការដ្ឋាន ។

**២- អនុគណៈកម្មការជំនាញ**

អនុគណៈកម្មការជំនាញមានចំនួន ២ សំរាប់អនុវត្តភារកិច្ច ដូចដែលមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យ ស្តីពីការ បង្កើត **គ.ជ.ក.ស** ។

អនុគណៈកម្មការជំនាញមានតួនាទីជាជំនួយការអគ្គលេខាធិការដ្ឋានលើការងារសំរបសំរួល តាមដានត្រួតពិនិត្យវាយតំលៃ ផ្តល់យោបល់ ផ្តល់អនុសាសន៍ និងជំរុញការអនុវត្តន៍គោលនយោបាយជាតិ ច្បាប់ជាតិ ការអនុវត្តន៍ កិច្ចព្រមព្រៀងច្បាប់អន្តរជាតិនានាដែលពាក់ព័ន្ធនឹងសិទ្ធិនារី និង វិធានការដែលទាក់ទងដល់ការលើកកំពស់ស្ថានភាព តួនាទី និង សុខុមាលភាព សង្គមស្ត្រីកម្ពុជា ។

អនុគណៈកម្មការជំនាញនីមួយៗមានភារកិច្ចដូចតទៅ :

**ក-អនុគណៈកម្មការជំនាញផ្នែកសំរបសំរួល ជំរុញការអនុវត្តន៍គោលនយោបាយ ច្បាប់ជាតិ បទបញ្ជា និងវិធានការដែលពាក់ព័ន្ធនឹងស្ត្រី**

- សិក្សា និងជំរុញការអនុវត្តន៍គោលនយោបាយជាតិ
- សិក្សាស្រាវជ្រាវអំពីច្បាប់ជាតិ បទបញ្ជា និងវិធានការ
- សំរបសំរួល សហប្រតិបត្តិការជាមួយបណ្តាក្រសួង អន្តរក្រសួង អង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្រុមឯកទេស នានា និងក្រុមព្រឹក្សាជាតិនៃប្រទេសដទៃទៀត
- ផ្សព្វផ្សាយតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាព
- ចងក្រង និងផលិតឯកសារផ្សេងៗ

**ខ-អនុគណៈកម្មារជំនាញ ផ្នែកតាមដានអនុវត្តន៍កិច្ចព្រមព្រៀងច្បាប់អន្តរជាតិ ពាក់ព័ន្ធសិទ្ធិនារី និងរៀបចំរបាយការណ៍អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW)**

- ពិនិត្យរៀបចំរបាយការណ៍ CEDAW ផ្តល់យោបល់លើការអនុវត្តន៍ដាក់ជូន **គ.ជ.ក.ស.** ដើម្បីពិនិត្យសំរេច និងផ្ញើរជូនរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវ ពីអនុសញ្ញាអន្តរជាតិ នានា ដែលពាក់ព័ន្ធនឹងសិទ្ធិនារី និងចងក្រង ឯកសារដើម្បីផ្សព្វផ្សាយ
- ពិនិត្យតាមដានការបញ្ជ្រាបយេនឌ័រ ដល់មន្ត្រីរាជការ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ៧.-**

- អនុគណៈកម្មការជំនាញនីមួយៗ ត្រូវដឹកនាំដោយអគ្គលេខាធិការរងនៃក្រុមព្រឹក្សារជាតិកម្ពុជាដើម្បីស្ត្រី
- ប្រធានផ្នែកបូកសរុប និងហិរញ្ញកិច្ច និងសមាជិកា-សមាជិក របស់ងអនុគណៈកម្មការជំនាញត្រូវជ្រើសរើសដោយប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្នុងចំណោមមន្ត្រីរាជការទាំងពីរភេទដែលមានក្របខ័ណ្ឌស្រាប់

អង្គការលេខនៃរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ**ក.ជ.ក.ស.**មានដូចក្នុង ឧបសម្ព័ន្ធភ្ជាប់និង អនុក្រឹត្យនេះ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិង អនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាជិក សមាជិកា ទាំងអស់នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

**សម្តេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា**
**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងជា**
**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី**

**ចូរ សុខហួរ**

**<u>កន្លែងទទួល :</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យ ១១០ អនក្របក ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០២**
**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក..ជ.ក.ស**

**<u>អង្គការលេខ</u>**

